**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ៣៤៤ សទណ.១១១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសហគមន៍ទេសចរណ៍អាស៊ាន (ASEAN Community-Based Tourism Standard) លើកទី៥ ឆ្នាំ២០២៦-២០២៧ និងស្តង់ដាផ្ទះស្នាក់សហគមន៍ទេសចរណ៍អាស៊ាន (ASEAN Homestay Standard) លើកទី៦ ឆ្នាំ២០២៦-២០២៨

ក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ សូមជម្រាបជូន លោក លោកស្រីប្រធានសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ម្ចាស់ផ្ទះស្នាក់សហគមន៍ និងប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ជ្រាបថា លេខាធិការដ្ឋានអាស៊ាន នឹងផ្តល់ជូនរង្វាន់ជ័យលាភី "ស្តង់ដាសហគមន៍ទេសចរណ៍អាស៊ាន ឆ្នាំ២០២៦-២០២៧" និង "ស្តង់ដាផ្ទះស្នាក់សហគមន៍អាស៊ាន ឆ្នាំ២០២៦-២០២៨" សម្រាប់ប្រទេសសមាជិកអាស៊ាន ដែលនឹងចែកជ័យលាភី នាឱកាសវេទិកាទេសចរណ៍អាស៊ាន (ATF) លើកទី៤៤ នាអំឡុងខែមករា ឆ្នាំ២០២៧ នៅប្រទេសសិង្ហបុរី។

ក្នុងន័យនេះ ក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ សូមធ្វើការណែនាំដល់ លោក លោកស្រីប្រធានសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ម្ចាស់ផ្ទះស្នាក់សហគមន៍ និងប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត អំពីនីតិវិធីនៃការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសហគមន៍អាស៊ាន និងស្តង់ដាផ្ទះស្នាក់សហគមន៍អាស៊ាន ដូចខាងក្រោម៖

❖ **ដំណាក់កាលទី១៖ ចាប់ពីថ្ងៃទី១ ខែកញ្ញា ដល់ថ្ងៃទី១ ខែតុលា ឆ្នាំ២០២៦**

បេក្ខភាព អាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាទាំងពីរខាងលើដោយផ្ទាល់នៅក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍រាជធានី ខេត្ត រៀងរាល់ម៉ោងធ្វើការ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងទូរសព្ទលេខ/ តេលេក្រាម៖ ០៩៧ ៤០ ៨៧ ៩៨០។

❖ **ដំណាក់កាលទី២៖ ចាប់ពីថ្ងៃទី២ ខែតុលា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៦**

គណៈកម្មការវាយតម្លៃ នឹងធ្វើការត្រួតពិនិត្យ និងចុះវាយតម្លៃផ្ទៀងផ្ទាត់ឯកសារពាក់ព័ន្ធ និងស្ថានភាពជាក់ស្តែងរបស់បេក្ខភាពដែលបានដាក់ពាក្យចូលរួមស្នើសុំវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាខាងលើ។

❖ **ដំណាក់កាលទី៣៖ ចាប់ពីថ្ងៃទី១៦ ខែតុលា ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៦**

គណៈកម្មការវាយតម្លៃ នឹងប្រមូលទិន្នន័យ និងរៀបចំរបាយការណ៍ចុងក្រោយ ដើម្បីឈានទៅប្រកាសលទ្ធផលជ័យលាភី។

❖ **ដំណាក់កាលទី៤៖ ខែធ្នូ ឆ្នាំ២០២៦**

គណៈកម្មការវាយតម្លៃ នឹងជូនដំណឹងអំពីជ័យលាភីដល់បេក្ខភាពដែលបានស្នើសុំវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាទាំងពីរខាងលើ។

ដីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Website: www.tourism.gov.kh
Telegram: t.me/motgovkh
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨៩ ៨៩៨
E-mail: admin@tourism.gov.kh

❖ ដំណាក់កាលទី៥៖ ខែមករា ឆ្នាំ២០២៧

បេក្ខភាពជ័យលាភី នឹងឡើងទៅទទួលពានរង្វាន់ជ័យលាភី នាឱកាសវេទិកាទេសចរណ៍អាស៊ាន (ATF) លើកទី៤៤ នៅប្រទេសសិង្ហបុរី។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រីប្រធានសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ម្ចាស់ផ្ទះស្នាក់សហគមន៍ទាំងអស់ ចូលរួមដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាខាងលើ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ថ្ងៃព្ហ ៦ កើត ខែ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ សីហា ឆ្នាំ២០២៦

ក្រសួងទេសចរណ៍

**ចម្លងជូន៖**

- រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងមុខការអនុវត្ត"
- ឯកសារ កាលប្បវត្តិ